**បញ្ឈប់ការយកអនាគតយើងធ្វើជាល្បែង**
**សម្ព័ន្ធការពារទន្លេមេគង្គ**
**អំពាវនាវអោយមានការលុបចោលគម្រោងទំនប់វារីអគ្គិសនីដន សាហុង**

នៅក្នុងឱកាសនៃ កិច្ចពិគ្រោះយោបល់ជាសាធារណៈថ្នាក់តំបន់របស់គណៈកម្មការទន្លេមេគង្គ ចំពោះទំនប់ដនសាហុង នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៤នេះ សម្ព័ន្ធការពារទន្លេមេគង្គ សូមរំលឹកឡើងវិញនូវការទាមទារអោយមានការលុបចោលនូវគម្រោងទំនប់ដនសាហុង និងអោយមានការការពារទន្លេមេគង្គ។ ទំនប់វារីអគ្គិសនី ដន សាហុង បង្កអោយមានហានិភ័យដែលមិនអាចទទួលយកបានទៅដល់វិស័យជលផលនិងសុវត្ថិភាពស្បៀងអាហារនៅក្នុងតំបន់ នឹងអាចធ្វើឲ្យអនាគតរបស់ទន្លេមេគង្គ និងមនុស្សនៅតំបន់នេះឋិតក្នុងភាពគ្រោះថ្នាក់។

គម្រោងទំនប់ដនសាហុងនឹងបណ្តាលអោយតំបន់ដែលមានប្រព័ន្ធអេកូឡូស៊ីដ៏មានសារៈសំខាន់និងកម្រនៃទន្លេមេគង្គ (ដែលត្រូវបានគេស្គាល់ដោយសារជីវចម្រុះទន្លេនិងជលផលដ៏សម្បូរបែប) នេះឋិតក្នុងភាពគ្រោះថ្នាក់។ ច្រកទឹកហ្សូរសាហុង ដែលទំនប់ដនសាហុងនឹងត្រូវសាងសង់លើនោះ គឺជាច្រកទឹកដ៏សំខាន់មួយដែលត្រីអាចឆ្លងកាត់ពេញមួយឆ្នាំរវាង ប្រទេសកម្ពុជា ថៃ ឡាវ និងវៀតណាម។ យ៉ាងហោចណាស់ពូជត្រីប្រមាណ១០០ប្រភេទត្រូវបានដឹងថាឆ្លងកាត់តាមច្រកទឹកនេះ។ ការរាំងស្ទះច្រកទឹកហ្សូរសាហុង នឹងបណ្តាលអោយមានផលប៉ះពាល់ដែលមិនអាចប៉ះប៉ូវបាន ទៅលើបំលាស់ទីរបស់ត្រី ព្រមទាំងផលវិបាកដល់សុវត្ថិភាព ស្បៀងអាហារ និងជីវភាពទូទាំងតំបន់មេគង្គទាំងមូល។

ការសិក្សាហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងទំនប់វារីអគ្គិសនីដនសាហុង ខកខានមិនបានដោះស្រាយអោយបានត្រឹមត្រូវនូវកត្តាគំរាមកំហែងទៅលើវិស័យជលផលនៅក្នុងតំបន់។ ក្រៅពីគម្រោងនេះមានទីតាំងតិចជាង២គីឡូម៉ែត្រពីកម្ពុជា ផលប៉ះពាល់ឆ្លងដែននៃគម្រោងនេះមិនទាន់ត្រូវបានពិចារណាពិសិក្សាអោយបានត្រឹមត្រូវនៅឡើយទេ។

ការសាងសង់ និងដំណើរការនៃទំនប់ដនសាហុងនឹងធ្វើអោយមានការផ្លាស់ប្តូរប្រព័ន្ធជលសាស្ត្រនៅក្នុងតំបន់ បង្កើនរដូវរាំងស្ងួតនៃលំហូររបស់ទន្លេមេគង្គដែលហូរតាមរយៈច្រកទឹកហ្សូរសាហុង ពី៤%ទៅ៥០%។ ការផ្លាស់ប្តូរនេះអាចប៉ះពាល់ដល់រមនីយដ្ឋានទឹកធ្លាក់ "ខោនផាក់ផេង" ដ៏ល្បីឈ្មោះ ព្រមទាំងគម្រាមកំហែងដល់តំបន់ដីសើមដែលត្រូវបានការពារជាសាកល នៅក្នុងតំបន់ "រ៉ាំសារ" ខេត្តស្ទឹងត្រែង ខ្សែទឹកខាងក្រោមនៃប្រទេសកម្ពុជា។

ផែនការបញ្ចៀសផលប៉ះពាល់ដែលបានស្នើឡើង ផ្អែកទៅលើភាពជោគជ័យរបស់គម្រោងណាមួយនោះ មិនដែលបានធ្វើតេស្តសាកល្បងនៅឡើយទេនៅក្នុងតំបន់ទន្លេមេគង្គ។ អ្នកជំនាញថ្នាក់តំបន់បានសម្តែងនូវភាពភ័យខ្លាចថា រង្វាស់បញ្ចៀសផលប៉ះពាល់នេះនឹងមិនមានប្រសិទ្ធិភាពដើម្បីបញ្ចៀសនូវការបាត់បង់ច្រកទឹកហួរសាហុងសម្រាប់ការធ្វើបំលាស់ទីរបស់ត្រី។ ការសិក្សាផ្សេងៗដែលបានផ្សព្វផ្សាយជាសាធារណៈដោយអ្នកអភិវឌ្ឍន៍គម្រោងនោះ គឺខកខានមិនបានរាប់បញ្ចូលភាពសម្បូរបែបផ្សេងៗគ្នានៃពូជត្រីនៅក្នុងតំបន់ ប្រភេទនីមួយៗមានចរិតលក្ខណៈនិងរបៀបបំលាស់ទីដោយឡែកៗពីគ្នា។ ដោយគ្មានទិន្នន័យច្បាស់លាស់អំពីការព្រួយ បារម្ភលើប្រភេទត្រីដែលផ្លាស់ទីឡើងតាមច្រកទឹកនីមួយៗនៅក្នុងតំបន់ល្បាក់ខោននោះ វានឹងមិនអាចទស្សទាយថាអ្វីជាផលប៉ះពាល់ដ៏ពិតប្រាកដនៃទំនប់ដនសាហុងដែលនឹងមាន ទាំងនៅក្នុងប្រទេសឡាវ និងនៅក្នុងតំបន់។ លើសពីនេះទៅទៀតអ្នកអភិវឌ្ឍន៍គម្រោងនេះមិនបានផ្តល់ព័ត៌មានដែលបង្ហាញថា ប្រភេទត្រីណាមួយដែលបានផ្តោតឡើងនៅក្នុងរង្វាស់បញ្ចៀសផលប៉ះពាល់ ឬក៏ការរៀបចំនៃច្រកទឹកនានាត្រូវបានជ្រើសរើសដើម្បីបញ្ចៀសផលប៉ះពាល់លើរបៀបបំលាស់ទីរបស់ប្រភេទត្រីនីមួយៗឡើយ។ ការសម្រេចចិត្តទាំងឡាយត្រូវបានធ្វើឡើងទាក់ទងនឹងការរៀបចំ និងដំណើរការនៃទំនប់ដនសាហុងគឺផ្អែកទៅលើការប៉ាន់ស្មានដែលដាក់ជាល្បែងភ្នាល់គ្នាចំពោះអនាគតរបស់ទន្លេមេគង្គ និងមនុស្សនៅក្នុងតំបន់ទន្លេមេគង្គ។

**មានការប្រថុយប្រថានច្រើនពេកហើយក្នុងការភ្នាល់របៀបនេះ!**

នៅក្នុងលិខិតមួយច្បាប់ផ្ញើទៅកាន់នាយករដ្ឋមន្ត្រីនានា នៃប្រទេសតំបន់ទន្លេមេគង្គ នាថ្ងៃទី១០ ខែ កញ្ញា ឆ្នាំ២០១៤ សម្ព័ន្ធការពារទន្លេមេគង្គ បានលើកឡើងនូវក្តីបារម្ភផ្សេងៗអំពីភាពស្របច្បាប់នៃដំណើរការពិគ្រោះយោបល់ជាមុនរបស់ទំនប់ដនសាហុងនេះ។ យើងបានសង្កត់ធ្ងន់ថា មិនមានគម្រោងណាមួយ រួមទាំងដនសាហុង គួរត្រូវបានដាក់ជូនជាផ្លូវការដើម្បីធ្វើការពិនិត្យទេ រហូតដល់ភាពខ្វះខាតសំខាន់ៗនៅក្នុងដំណើរការកិច្ចពិគ្រោះយោបល់ជាមុន ក្នុងកំឡុងពេលសិក្សាអំពីទំនប់សាយ៉ាប៊ូរីត្រូវបានដោះស្រាយជាមុន ហើយរហូតដល់ការសិក្សាដ៏ត្រឹមត្រូវ រួមទាំងការសិក្សាស្រាវជ្រាវដោយក្រុមប្រឹក្សា និង ដីសណ្តរទន្លេមេគង្គ (Council and Delta Study) ទាំងឡាយត្រូវបានបញ្ចប់ ហើយផ្សព្វផ្សាយជាសាធារណៈ។ នៅក្នុងលិខិតដដែលនេះ សម្ព័ន្ធការពារទន្លេមេគង្គ បានដាក់បញ្ចូលនូវអនុសាសន៍នានាសម្រាប់កាត់បន្ថយលក្ខណៈវិនិច្ឆ័យ ដោយយោងទៅលើស្តង់ដារអន្តរជាតិនានា ដើម្បី

ជម្រុញអោយមានដំណើរការពិគ្រោះយោបល់ដែលមានការចូលរួម និងមានតម្លាភាពមួយ ដោយរួមបញ្ចូលនូវតម្រូវការអោយមានការពិគ្រោះយោបល់ដ៏មានអត្ថន័យមួយមុនពេលមានការសម្រេចចិត្តបន្តគម្រោងឬអត់ ហើយទាមទារអោយដំណើរការ និងស្តង់ដារសម្រាប់ការពិគ្រោះយោបល់មានភាពដូចគ្នាទូទាំងតំបន់ដើម្បីធ្វើអោយប្រាកដថា កង្វល់នៃប្រទេសទាំងអស់ត្រូវបានលើកឡើង កត់ត្រា និងពិចារណាដោយស្មើៗគ្នា។ នាពេលបច្ចុប្បន្ន វាច្បាស់ណាស់ថាតម្រូវការជាមូលដ្ឋានទាំងនេះមិនត្រូវបានលើកឡើងនៅក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ ដែលកំពុងដំណើរការនៅក្នុង ប្រទេសកម្ពុជា និងថៃ។

ដំណើរការ កិច្ចពិគ្រោះយោបល់ជាមុននៃទំនប់ដនសាហុង នឹងមិនត្រូវបានប្រើជាមធ្យោបាយសម្រាប់រដ្ឋាភិបាលឡាវក្នុងការធ្វើឲ្យការសាងសង់នេះក្លាយជាស្របច្បាប់ក្រោមកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥។ ប៉ុន្តែវាគួរតែបង្ហាញពីឆន្ទៈល្អនៃការសម្រេចចិត្តថ្នាក់តំបន់ និង ក្នុងន័យពង្រឹងកិច្ចព្រមព្រៀងឆ្នាំ១៩៩៥។ វាគឺសំខាន់ណាស់ដែលការសម្រេចចិត្តទាក់ទងនឹងការអភិវឌ្ឍន៍ទន្លេមេនៃទន្លេមេគង្គគឺផ្តោតលើការព្រមព្រៀងរវាងភាគីសមាជិកទាំងអស់ ហើយកាន់តែសំខាន់ជាងនេះទៅទៀតនោះគឺប្រជាពលរដ្ឋរាប់លាននាក់នៅក្នុងតំបន់ដែលពឹងផ្អែកលើធនធាននិងជីវចម្រុះនៃទន្លេមេគង្គ។

ទន្លេមេគង្គជាប្រព័ន្ធអេកូឡូស៊ីសំខាន់មួយនៃពិភពលោកដែលទ្រទ្រង់ជីវិត និងជីវភាពប្រជាពលរដ្ឋទាំង៤ប្រទេស។ តួនាទីនៃមេគង្គ និងប្រជាជនរបស់វាគឺតំណាងឲ្យ តំបន់សម្បូរដោយធនធានជលផល។ ផលប៉ះពាល់ពីទំនប់ដនសាហុងទៅលើបម្លាស់ទីរបស់ត្រី និង ផលិតផលត្រី ធ្វើឲ្យមានហានិភ័យដែលមិនអាចទទួលយកបានចំពោះសុវត្ថភាពស្បៀង ជីវិត ជីវភាពរស់នៅ និង សុខភាពរបស់ប្រជាពលរដ្ឋរាប់លាននាក់។ ជាងនេះទៅទៀត ការបរាជ័យក្នុងកិច្ចសហការក្នុងតំបន់ និង ផលចំណាយដែលមិនមានសមភាពនឹងធ្វើឲ្យមានការគំរាមកំហែងដល់ស្ថេរភាពទាំងផ្នែកសេដ្ឋកិច្ច និងផ្នែកសន្តិសុខនយោបាយក្នុងតំបន់ទន្លេមេគង្គទាំងមូល។ វិធីសាស្ត្របង្ការគឺជាការចាំបាច់មួយដើម្បីធានានូវអនាគតប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន និងអនាគតជំនាន់ក្រោយដែលពឹងផ្អែកលើទន្លេមេគង្គ។ ការខិតខំប្រឹងប្រែងមួយត្រូវតែបានធ្វើឡើងដោយអ្នកដឹកនាំថ្នាក់តំបន់ដើម្បីជម្រុញដល់ការរៀបចំផែនការថាមពលឲ្យប្រសើរ និងជ្រើសរើសយកជម្រើសថាមពលណាដែលមាននិរន្តរភាពដើម្បីធានាឲ្យបាននូវអនាគតរបស់ទន្លេមេគង្គ។

ហានិភ័យដែលបង្កឡើងដោយទំនប់វារីអគ្គិសនីដនសាហុងនេះ គឺបញ្ចៀសបាន។ ដូច្នេះ យើងសូមអំពាវនាវដល់រដ្ឋាភិបាលឡាវលុបចោល គម្រោងទំនប់វារីអគ្គិសនីដនសាហុងនេះជាបន្ទាន់ ហើយសម្រាប់រាជរដ្ឋាភិបាលប្រទេសកម្ពុជា ថៃ និង រដ្ឋាភិបាលវៀតណាម ត្រូវចាត់វិធានការចាំបាច់ណាមួយ

ដើម្បីលើកកម្ពស់ការទទួលខុសត្រូវរបស់ខ្លួនក្នុងការការពារទន្លេមេគង្គ និងប្រជាជនរបស់ខ្លួន។ ជាមួយគ្នានេះ មេដឹកនាំក្នុងតំបន់ទន្លេមេគង្គ ត្រូវតែចាត់វិធានការជាបន្ទាន់ដើម្បីកែលម្អកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងដើម្បីធានានូវការការពាររយៈពេលវែងដល់ធនធានសំខាន់ៗនៅក្នុងទន្លេមេគង្គ។

សម្ព័ន្ធការពារទន្លេមេគង្គ គឺជាសម្ព័ន្ធនៃចម្រុះអង្គការមិនមែនរដ្ឋាភិបាល ជាប្រជាជនក្នុងតំបន់ អ្នកសិក្សាស្រាវជ្រាវ សារព័ត៌មាន និងក្រុមប្រជាជនសាមញ្ញដែលមកពីបណ្ដាប្រទេសក្នុងតំបន់មេគង្គ និងអន្តរជាតិ ដើម្បីធ្វើការរួមក្នុងការថែរក្សាទន្លេមេគង្គ។